**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
CNMC
Cambodia National Mekong Committee

**គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា**

លេខ : ១៦០ គ.ជ.ទ.ម.ក

ថ្ងៃពុធ ៦ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៨

**ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា**

**សូមគោរព និងជម្រាបជូន**

- **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**
- **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី ទទួលបន្ទុកអនុប្រធានប្រចាំការ និងជាប្រធានគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងបរិស្ថាន**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល**
- **លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**
- **ឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប**
- **ឯកឧត្តមអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
- **ឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាល័យភូមិន្ទកសិកម្ម**
- **ឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាល័យភូមិន្ទភ្នំពេញ**
- **ឯកឧត្តមអគ្គនាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

**កម្មវត្ថុ:** សំណើសុំជួយផ្សព្វផ្សាយដំណឹង ស្តីពីការជ្រើសរើសនាយកប្រតិបត្តិនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គអាណត្តិ(២០១៩-២០២១) បម្រើការងារនៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថាៈ ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ(MRC) កម្ពុជា ឡាវ ថៃ និងវៀតណាម បានឯកភាពគ្នាសម្រេចជ្រើសរើសនាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC ចេញពីប្រទេសសមាជិក សម្រាប់អាណត្តិ៣ឆ្នាំដោយ

អគារលេខ 576, ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ 2214 ភ្នំពេញ 3
ទូរស័ព្ទ : (855-23) 216 514 ទូរសារ : (855-23) 218 506 អ៊ីម៉ែល : cnmcs@cnmc.gov.kh Website : www.cnmc.gov.kh

ក្នុងនោះនាយកប្រតិបត្តិទី១ ត្រូវបានជ្រើសរើសចេញពីប្រទេសវៀតណាម(២០១៦-២០១៨) និងបានឯកភាពប្តូរវេន សម្រាប់មុខតំណែងនេះ ក្នុងចំណោមប្រទេសជាសមាជិកតាមលំដាប់តួអក្សរឡាតាំង(V-C-L-T)។ ផ្អែកលើគោលការណ៍ឯកភាពគ្នានេះ នាយកប្រតិបត្តិបន្ទាប់សម្រាប់ឆ្នាំ២០១៩-២០២១ នឹងត្រូវជ្រើសរើសចេញពីប្រទេសកម្ពុជា និងត្រូវបម្រើការងារនៅទីស្នាក់ការលេខាធិការដ្ឋានMRC ដែលមានទីតាំងនៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ក្នុងន័យនេះ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សូមធ្វើការប្រកាសផ្សព្វផ្សាយដំណឹងជ្រើសរើសនាយកប្រតិបត្តិនៃMRCS ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមានចុះផ្សាយតាមរយៈកាសែតក្នុងស្រុក (កាសែតរស្មីកម្ពុជា និងភ្នំពេញប៉ុស្តិ៍) ដើម្បីស្វែងរកមន្ត្រីដែលមានសមត្ថភាពខ្ពស់សមស្រប ដើម្បីបំពេញមុខងារជានាយកប្រតិបត្តិនៃលេខាធិការដ្ឋានMRC(MRCS-CEO) សម្រាប់អាណត្តិ៣ឆ្នាំ(២០១៩-២០២១)។ បេក្ខជនដាក់ពាក្យសុំត្រូវមានលក្ខណៈសម្បត្តិ និងត្រូវបំពេញល័ក្ខខ័ណ្ឌនៃការជ្រើសរើសដូចមានក្នុងឯកសារជូនភ្ជាប់។ កាលបរិច្ឆេទឈប់ទទួលពាក្យសុំផុតកំណត់នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨។ ព័ត៌មានលំអិតពាក់ព័ន្ធនឹងការដាក់ពាក្យសុំនេះ សូមទំនាក់ទំនងមកអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា តាមរយៈលោក **អ៊ូ សុផាណា** ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (អ៊ីម៉ែល: u_sophanna@yahoo.com ទូរស័ព្ទលេខ: 011472052) និងលោក **ស៊ិន សំណាង** ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៏ធនធានមនុស្ស (អ៊ីម៉ែល: sinsamnang9@gmail.com និង ទូរស័ព្ទលេខ:012 636 689)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាពិនិត្យ និងសុំជួយសម្រួលផ្សព្វផ្សាយព័ត៌មាន *ស្តីពីការជ្រើសរើសមន្ត្រីកម្ពុជា សម្រាប់មុខតំណែងជានាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC សម្រាប់ឆ្នាំ២០១៩-២០២១* ឲ្យបានទូលំទូលាយ តាមការគួរ។

សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរព និងរាប់អានដ៏ស្មោះអំពីខ្ញុំ។

ប្រធាន

លឹម គានហោ

**ចម្លងជូន:**

- ក្រសួងធនធានទឹក និងឧតុនិយម
- អង្គភាពមេគង្គប្រចាំក្រសួង
- ឯកសារ-កាលប្បវត្តិ